ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥២/២០ - ឃ្វីនធ័ មេជើរ អ៊ិនដាសស្រ្ទៀល
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឃ្វីនធ័ មេជើរ អ៊ិនដាសស្រ្ទៀល ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល
ទូរស័ព្ទ ៖ ០១២ ៨២ ៧៧ ៥៥ / ០៧០ ៧០ ៧០ ៣៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១៖

| | |
|---|---|
| ១- លោក ស្រ៊ី គីមយូ | មេធាវីក្រុមហ៊ុន |
| ២- លោក David Liv | ប្រធានគ្រប់គ្រង |
| ៣- លោក កុល វត្ថា | ប្រធានផ្នែករដ្ឋបាល |
| ៤- លោក ជួន អ៊ុកសុវណ្ណថា | បុគ្គលិកធនធានមនុស្ស |
| ៥- លោកស្រី ស៊ុន សេរី | ផ្នែករដ្ឋបាល |

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២៖

| | |
|---|---|
| ១- លោក ស្រ៊ី គីមយូ | មេធាវីក្រុមហ៊ុន |
| ២- លោក David Liu | ប្រធានគ្រប់គ្រង |
| ៣- លោក កុល វត្ថា | ប្រធានផ្នែករដ្ឋបាល |
| ៤- លោក ជួន អ៊ុកសុវណ្ណថា | បុគ្គលិកធនធានមនុស្ស |
| ៥- លោកស្រី ស៊ុន សេរី | ផ្នែករដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងឈើនាង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០៨៧ ៧៧៧ ៨១៩ / ០៩៨ ៦៦ ៨៥ ៣៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ុត | មន្ត្រីច្បាប់ ស៊ីខៅឌូ |
| ២- លោក ស៊ី វ៉ាន់ជា | មន្ត្រីច្បាប់ ស៊ីខៅឌូ |
| ៣- លោក សៀង វដ្ឋា | តុកាត់ |
| ៤- លោក ហ៊ុល វដ្ឋា | ឃ្លាំង |
| ៥- លោក អៀង ស៊ីថា | តុកាត់ |
| ៦- លោក ម៉ុន សុខលាង | ឃ្លាំង |
| ៧- លោក ហំ សុខហៀង | តុកាត់ |
| ៨- លោក សុទ្ធ ហ៊ីរ | តុកាត់ |
| ៩- លោក យ៉ែម ថារាជ | តុកាត់ |
| ១០- លោក ចន្ថា សំណាង | តុកាត់ |

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងមកលើសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី។ ភាគីក្រុមហ៊ុនពុំមានការរើសអើងសហជីពប្រជាធិបតេយ្យកម្មករទេ ដោយសារក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារកម្មករទាំងអស់ ហើយចំពោះការបញ្ចប់កិច្ចសន្យាដោយសារក្រុមហ៊ុនពុំសូវមានការងារធ្វើ។ ភាគីកម្មករមិនឯកភាពដោយក្រុមហ៊ុនបញ្ឈប់ភាគីសមាជិក និងសកម្មជនរបស់សហជីពខាងលើ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នា

THE ARBITRATION COUNCIL

ឡើយ ហើយរបាយការណ៍ស្ដីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ីនធ័ មេជើរ អ៊ិនដាសស្រ្ទៀល ខូអិលធីឌី លេខ ៥៤១/២០ ក.ប/កណ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖**

- **លើកទី១ ៖** ថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។
- **លើកទី២ ៖** ថ្ងៃចន្ទ ១០រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលលិខិតស្នើសុំជួយអន្តរាគមន៍ឱ្យនិយោជកដោះស្រាយនូវវិវាទការងាររួម ដែលពាក់ព័ន្ធនឹងករណីទាមទាររបស់កម្មករនិយោជិតចំនួន ៣ចំណុច។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានអញ្ជើញភាគីពាក់ព័ន្ធទាំងអស់មកចូលរួមសម្របសម្រួល ដោយបានលទ្ធផលមិនសះជាចំនួន ១ ចំណុច។ ចំណុចវិវាទដែលមិនសះជាចំនួន ១ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ីនធ័ មេជើរ អ៊ិនដាសស្រ្ទៀល ខូអិលធីឌី លេខ ៥៤១/២០ ក.ប/កណ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ ចំនួន ២លើក គឺលើកទី១ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ នៅពេលចាប់ផ្តើមសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា បាត់ចំណុចវិវាទដែលមាននៅក្នុងបណ្តឹងដើមចំនួន ១ចំណុច ហេតុនេះ ភាគីកម្មករនិយោជិតស្នើសុំលើកពេលសវនាការ។ ដោយមានហេតុផលសមរម្យ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើកពេលសវនាការទៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ទន្ទឹមនឹងនេះដែរ ភាគីនិយោជកក៏បានស្នើសុំលើកពេលសវនាការបន្តទៀត ហើយភាគីកម្មករនិយោជិតបានឯកភាពទៅតាមការស្នើសុំលើកពេលនេះដែរ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើកពេលសវនាការ ទៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង០០ នាទី រសៀលវិញ។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជកមកសវនាការ តាមរយៈលិខិតអញ្ជើញលេខ ៣៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ និងបានអញ្ជើញភាគីកម្មករនិយោជិតមកសវនាការ តាមរយៈលិខិតអញ្ជើញលេខ ៣៤០ កប/អក/- វក/លកអ ចូលរួមសវនាការ នៅថ្ងៃសវនាការលើកទី២ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។

មុនពេលសវនាការលើកទី២នេះ ចាប់ផ្តើម មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បាន ទំនាក់ទំនងតាមទូរសព្ទទៅកាន់ភាគីកម្មករនិយោជិត លោក ស៊ាង យ៉ុត ដែលជាមន្ត្រីច្បាប់ បានបញ្ជាក់ថា កម្មករនិយោជិតនៃក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី សម្រេចចិត្តធ្វើពហិកាមិនចូលរួមសវនា-ការ សម្រាប់សំណុំរឿងលេខ ០៥២/២០-ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ដោយមូលហេតុចំនួន ២ គឺ មូលហេតុទីមួយៈ របាយការណ៍បញ្ជូនមកពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល មិនស្ថិតក្នុង បណ្តឹងដើមរបស់កម្មករនិយោជិត (បណ្តឹងដើមមាន ៥ចំណុច) ក្នុងរបាយការណ៍មានតែ ៣ចំណុច។ មូលហេតុ ទីពីរៈ បាត់ខ្លឹមសារនៅទំព័រទី៤ នៃកំណត់ហេតុផ្សះផ្សាចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។ លោក សៀង វឌ្ឍា ជាអ្នកតំណាងកម្មករនិយោជិត បានបញ្ជាក់ដែរថា តំណាងកម្មករនិយោជិតទាំងអស់ឯកភាពគ្នាមិនចូលរួម សវនាការនៃសំណុំរឿងលេខ ០៥២/២០-ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ដោយមូលហេតុ ថា ខាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បញ្ជូនរបាយការណ៍មិនសះជា មិនទាន់បាន ត្រឹមត្រូវ ពោលបាត់ចំណុចទាមទារមួយចំណុចរបស់ភាគីកម្មករនិយោជិត។

ភាគីនិយោជកមានវត្តមាននៅថ្ងៃសវនាការលើកទី២នេះ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុម-ប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ទាយក David Liv ប្រគល់សិទ្ធិជូន លោកមេធាវី ស្រ៊ី គីមយូ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

២- សារណាការពារ ចុះថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ចុះទិដ្ឋាការ លេខ ០០៣/០៧ កបវ/កណ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ ដោយប្រធានមន្ទីរការងារ និង បណ្តុះបណ្តាល-វិជ្ជាជីវៈខេត្តកណ្តាល។

៤- លក្ខន្តិកៈក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ចុះទិដ្ឋាការ លេខ ១៥៣៨/០៥ ចុះ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ នៅនាយកដ្ឋាននីតិវិធី និងច្បាប់វិនិយោគ គ.វ.ក។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី លេខ MOC- ៧១៦១៣៥៥៧ ពណ.ចបព ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦។

៦- ភស្តុតាងជាឯកសារសម្លេងកោះប្រជុំតំណាងប្រតិភូបុគ្គលិក សហជីពប្រជុំប្រចាំខែ។

៧- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃ ព្រហស្បតិ៍ ០៨រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី។

៨- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃព្រហស្បតិ៍ ០១រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

៩- កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី និងតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាននៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី ស្តីពី ការព្យួរកិច្ចសន្យាការងារ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០។

១០- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃសុក្រ ១០កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១១- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១២- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃពុធ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៣- កំណត់ហេតុកិច្ចប្រជុំជាមួយតំណាងសហជីពមូលដ្ឋាន ធ្វើនៅថ្ងៃសុក្រ ១៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៤- កំណត់ហេតុស្តីពីកិច្ចប្រជុំជាមួយតំណាងប្រតិភូបុគ្គលិក និងតំណាងសហជីព ធ្វើនៅថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៥- កំណត់ហេតុកិច្ចប្រជុំស្តីអំពីក្រុមហ៊ុនតម្រូវការកាត់បន្ថយកម្មករ-និយោជិតចំនួន ៩២នាក់ ចុះថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៦- កំណត់ហេតុស្តីពីកិច្ចប្រជុំជូនដំណឹងដល់តំណាងប្រតិភូបុគ្គលិក និងសហជីពអំពីការព្យួរកិច្ចសន្យាការងារ ធ្វើនៅថ្ងៃពុធ ១កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៧- កំណត់ហេតុកិច្ចប្រជុំស្តីពីជូនដំណឹងបញ្ចប់កិច្ចសន្យាការងារកម្មករនិយោជិត ជាមួយតំណាងប្រតិភូបុគ្គលិក និងសហជីព ធ្វើនៅថ្ងៃចន្ទ ១៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនជាសស្រៀល ខូអិលធីឌី។

១៨- កំណត់ហេតុកិច្ចប្រជុំស្តីពីជូនដំណឹងដល់តំណាងកម្មករនិយោជិត និងសហជីពអំពីការព្យួរកិច្ចសន្យាការងារ ធ្វើនៅថ្ងៃសៅរ៍ ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី។

១៩- កំណត់ហេតុកិច្ចប្រជុំស្តីពីជូនដំណឹងការព្យួរកិច្ចសន្យាការងាររយៈពេលលើសពី ២១ថ្ងៃ ធ្វើនៅថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី។

២០- កំណត់ហេតុកិច្ចប្រជុំស្តីពីការផ្លាស់ប្តូរការងារកម្មករ-កម្មការិនី ពីផ្នែកមួយទៅផ្នែកមួយ ធ្វើនៅថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី។

២១- កំណត់ហេតុកិច្ចប្រជុំស្តីពីការពិភាក្សាការកាត់ប្រាក់លើកទឹកចិត្តដែលក្រុមហ៊ុនផ្តល់បន្ថែមទៅលើលុយព្រីម នៅពេលកម្មករសុំច្បាប់ឈឺ ធ្វើនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី។

២២- លិខិតចុះថ្ងៃចន្ទ ១១កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ របស់លោកមេធាវី ស្រ៊ី គីមយូ ជាមេធាវីតំណាងក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំពន្យាពេលការចូលរួមសវនាការក្នុងសំណុំរឿងលេខ ០៥២/២០ នៅថ្ងៃទី០១ ខែតុលា វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក។

២៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៣៥ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

២៤- លិខិតអញ្ជើញ ចុះថ្ងៃពុធ ០៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ របស់រដ្ឋបាលរាជធានីភ្នំពេញ សូមអញ្ជើញឯកឧត្តម ស្រ៊ី គីមយូ សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ ឆ្នាំ២០២០ នៅខណ្ឌព្រែកព្នៅ។

២៥- ឯកសារជារូបភាព។

២៦- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចាត់តាំងលោក ស៊ាង យ៉ូត ជាមន្ត្រីដោះស្រាយវិវាទរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី លេខ ៥៤/២០ ស.ប.ក/វិវាទ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

២- ពាក្យបណ្តឹងចុះថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់តំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ឃ្វីនធ៍ មេដើរ អ៊ិនដាសស្រៀល ខូអិលធីឌី គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ស្តីពីស្នើសុំ

អន្តរាគមន៍ឱ្យនិយោជកក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ដោះស្រាយការទាមទាររបស់កម្មករនិយោជិត។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី លេខ ០០០៦/១៨ ក.ប/កណ ចុះថ្ងៃសុក្រ ១០កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨។

៤- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី លេខ ០៩៧/១៩ ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

៥- លិខិតលេខ ៣១/២០ ក.ប/កណ ចុះថ្ងៃពុធ ៤កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ជម្រាបមក លោកប្រធានសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាស-ស្ទ្រៀល ខូអិលធីឌី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

៦- ញត្តិទាមទារ និងចាត់តាំងអ្នកតំណាង ចុះថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន នធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

៨- ពាក្យបណ្តឹង ប្រគល់សិទ្ធិ និងចាត់តាំងអ្នកតំណាង របស់កម្មករនិយោជិតនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី គោរពជូន លោកប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីសូមប្រគល់សិទ្ធិ និងចាត់តាំងអ្នកតំណាង ដើម្បីដោះស្រាយជូនខ្ញុំបាទ/នាងខ្ញុំ នូវគ្រប់ដំណើរការនីតិវិធីទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ ព្រមទាំងតាក់តែងលិខិតស្នាមផ្សេងៗ រហូតដល់ចប់រឿងក្តី។

៩- តារាងបើកប្រាក់ឈ្នួល, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, កាតសម្គាល់ខ្លួន និងប័ណ្ណសំគាល់ថ្នាក់ដឹកនាំ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិល-ធីឌី លេខ ៥៤១/២០ ក.ប/កណ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុនឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី លេខ ០០៧/២០ ក.ប/កណ ចុះថ្ងៃទី ខែ ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣២៥ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១៣ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣២៦ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣២៧ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣២៨ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៣៥ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៣៦ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

៧- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣៣៩ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

៨- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣៤០ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពុំមានអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងបានធ្វើពហិកាមិនចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាល ឬត្រូវបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនព្រមចូលរួមសវនាការអាជ្ញាកណ្តាល?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាល ត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និង ដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"។*

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមក្នុងកិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"។*

THE ARBITRATION COUNCIL

ប្រការ ២១ នៃប្រកាសដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ ហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

យោងតាមប្រការ ១៨, ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ដែលបានលើកឡើងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញា-កណ្តាលមានកាតព្វកិច្ចអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត សម្រាប់ឱ្យក្រុមប្រឹក្សា-អាជ្ញាកណ្តាលធ្វើការសម្រេចសេចក្តី។ ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុម-ប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ដែលបានលើកឡើងខាងលើនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន និងមិនចូលរួមសវនាការ។ *(សូមមើលបន្ថែមសំណុំរឿងលេខ ១៦/០៧-ឡូទូសគី, លេខ ២៧/០៧-អ៊ីម និង រ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វ្រែង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/ ១៤-ធី & ខេ ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសវនាការលើកទី១ ភាគីទាំងពីរបានចូលរួមនៅក្នុងដំណាក់កាលណែនាំខ្លួន, ពន្យល់អំពីទំនាស់ផលប្រយោជន៍, និងដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ បន្ទាប់មកភាគីកម្មករនិយោជិតបានលើកឡើងថាបាត់ចំណុចវិវាទដែលមាននៅក្នុងបណ្តឹងដើមរបស់កម្មករនិយោជិត ហេតុនេះភាគីកម្មករ

និយោជិតស្នើសុំលើកពេលសវនាការទៅថ្ងៃក្រោយវិញ។ រហូតដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដែលជាថ្ងៃសវនាការលើកទី២ ភាគីកម្មករនិយោជិតបានធ្វើពហិការមិនចូលរួមសវនាការក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះទេ ដោយលើកមូលហេតុថា នៅក្នុងរបាយការណ៍បញ្ជូនមកពីមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល មិនស្ថិតក្នុងបណ្ដឹងដើមរបស់កម្មករនិយោជិត (បណ្ដឹងដើមមាន ៤ចំណុច) ក្នុងរបាយការណ៍មានតែ ៣ចំណុច និងបាត់ខ្លឹមសារនៅទំព័រទី៤ នៃកំណត់ ហេតុផ្សះផ្សាចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២០។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនអាចយកហេតុផល នៃការបាត់ចំណុចវិវាទដែលមាននៅក្នុងបណ្ដឹងរបស់ភាគីកម្មករនិយោជិត មកធ្វើពហិកាមិនចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបាននោះទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា ការដែលកម្មករនិយោជិតមិនចូលរួមសវនាការអាជ្ញាកណ្ដាលនេះ គឺជាការបោះបង់បណ្ដឹងរបស់របស់ខ្លួន។ យោងតាមខ្លឹមសារប្រការ ១៨, ប្រការ ២០, ប្រការ ២១ នៃប្រកាសលេខ ០៩៩ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ខាងលើ ក្រុម-ប្រឹក្សាអាជ្ញា-កណ្ដាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយសារអវត្តមានរបស់ភាគីកម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០៥២/២០-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី នេះ។

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៃសំណុំរឿងលេខ ០៥២/២០-ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល ខូអិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ីខ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ុន គឹមស៊ាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL